**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Jun-2014, 09:53
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា**
**ទៅនឹងសារណារបស់ នួន ជា និង ខៀវ សំផន ស្ដីពីអញ្ញត្រកម្ម**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

# ចម្លើយតបរួម

១. នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានបង្គាប់ឲ្យភាគីបញ្ជាក់ ថាតើពួកគេមានបំណងនៅប្រកាន់ជំហរចំពោះអញ្ញត្រកម្មជាក់លាក់ ដែលបានលើកឡើងដោយអតីតមេធាវី អៀង សារី[1] ដែររឬទេ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ ចម្លើយតបត្រូវបានធ្វើឡើងដោយមេធាវីការពារក្តី នួន ជា[2] និង ខៀវ សំផន[3]។ សហជនជាប់ចោទទាំងពីរ នៅតែរក្សាគោលជំហរដដែលចំពោះអញ្ញត្រកម្មរបស់ អៀង សារី ស្តីពីការអនុវត្តបទប្បញ្ញត្តិនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[4] ហើយ ខៀវ សំផន នៅតែរក្សាបន្ថែមទៀតលើអញ្ញត្រកម្មចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះ នៅក្នុងការស្តាប់សវនាការលើបទចោទនៃការនិរទេស ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[5] ដដែល។

២. សហព្រះរាជអាជ្ញានៅរក្សាគោលជំហរពីមុនរបស់ខ្លួន ទាំងនៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ដែលបានធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ស្តីពីអញ្ញត្រកម្មទាំងនេះ។ នៅក្នុងសារណាតបដ៏ខ្លីនេះសហព្រះរាជអាជ្ញាសូមបញ្ជាក់អំពីគោលជំហរពីមុនរបស់ខ្លួនថា៖

(ក) គ្មានច្បាប់អាជ្ញាយុកាលណារារាំងដល់ការអនុវត្តបទប្បញ្ញត្តិ នៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចំពោះសហជនជាប់ចោទទេ ពីព្រោះ *នៅក្នុងចំណោម*បញ្ញត្តិផ្សេងៗទៀត មាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែល អ.វ.ត.ក ត្រូវបានផ្តល់យុត្តាធិការនោះឡើយ ហើយច្បាប់ទម្លាប់អន្តរជាតិនាឆ្នាំ១៩៧៥ បានផ្តល់សិទ្ធិក្នុងការមិនអនុវត្តច្បាប់អាជ្ញាយុកាលក្នុងស្រុក ចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះ ដោយច្បាប់នេះមានចរិកលក្ខណៈជា*ច្បាប់ចាប់បង្ខំ*[6]។ ហើយ

---

[1] **E306** អនុស្សរណៈជូនចំពោះគូភាគី “ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងអញ្ញត្រកម្មដែលនៅសេសសល់”, ២៥ មេសា ២០១៤ ត្រង់កថាខណ្ឌ៥។

[2] **E306/1** គោលជំហរចំពោះអញ្ញត្រកម្មដែលនៅសេសសល់ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី, ២០ ឧសភា ២០១៤ (“សារណារបស់ នួន ជា”)។

[3] **E306/2** សេក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ស្តីពីអញ្ញត្តិកម្មដែលបញ្ហានោះអង្គជុំជម្រះមិនទាន់បានដោះស្រាយ ២០ ឧសភា ២០១៤ (“សារណារបស់ ខៀវ សំផន”)។

[4] **E306/1** សារណារបស់ នួន ជា, កំណត់សម្គាល់ខាងដើម *លេខ២* ត្រង់កថាខណ្ឌ១-២។

[5] **E306/2** សារណារបស់ ខៀវ សំផន, កំណត់សម្គាល់ខាងដើម *លេខ៣* ត្រង់កថាខណ្ឌ១៤-២០។

[6] **E51/5/3/1** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង, ២១ មីនា ២០១១ ត្រង់កថាខណ្ឌ៦។ **E1/5.1** ប្រតិចារឹក (សវនាការបឋម), 15.27.35-16.10.25។

(ខ) អង្គជំនុំជម្រះបានទទួលបណ្តឹងយ៉ាងត្រឹមត្រូវ អំពីការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងបទនិរទេសដែលទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញដោយបង្ខំពីខេត្តព្រៃវែង ស្វាយរៀង និងពីសហករណ៍នៅត្រាំកក់ ពីព្រោះសុពលភាពនៃយុត្តាធិការ *លើបណ្តឹងអំពីវត្ថុ* របស់សហចៅក្រមស៊ើបអង្កេតបានរួមបញ្ចូលនូវអង្គហេតុដើមអាទិ៍[7]នានា។

៣. ក្នុងការគាំទ្រដល់គោលជំហររបស់ពួកគេកាលពីមុន ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះរបបដែលរំលោភបំពាននានាយ៉ាងធ្ងន់ធ្ងរ សហព្រះរាជអាជ្ញា (ទីមួយ)សង្កេតឃើញថាក្រុមមេធាវីការពារក្តីរបស់ នួន ជា[8] និង ខៀវ សំផន[9] គ្រាន់តែបានរួមបញ្ចូលគ្នាដោយយោងទៅលើអញ្ញត្រកម្មដែលបានរៀបចំគំរោងដោយអតីតក្រុមមេធាវីការពារក្តីរបស់ អៀង សារី តែប៉ុណ្ណោះ។ ខ្លឹមសារនៃការជំទាស់នេះត្រូវបានធ្វើសវនាការស្តាប់រួចហើយ ហើយត្រូវបានបដិសេធដោយអង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿងលេខ០០២[10] និងដោយអង្គជំនុំជម្រះនេះនៅក្នុងសំណុំរឿងលេខ០០១[11]ជាលទ្ធផលពុំត្រូវបានរំខានលើបណ្តឹងឧទ្ធរណ៍ឡើយ។ ពុំមានក្រុមមេធាវីការពារក្តីណាមួយបានផ្តល់ជូននូវអំណះអំណាងតាមច្បាប់ដែលនឹងធ្វើយុត្តិកម្មឱ្យឃើញពីការឃ្លាតចាកពីយុត្តាធិការដែលបានរៀបចំយ៉ាងល្អរួចហើយនោះឡើយ។

៤. (ទីពីរ) គឺច្បាស់ណាស់ចំពោះមេធាវីការពារក្តី អៀង សារី ដែលថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនមាននិយាយដល់ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ឬការមិនអនុវត្តឧក្រិដ្ឋកម្មអន្តរជាតិណាមួយក៏ទេដែរ ប៉ុន្តែគ្រាន់តែនិយាយថា "បទឧក្រិដ្ឋ"[12]។ សហព្រះរាជអាជ្ញាសូមធ្វើការអះអាងបញ្ជាក់អំពីសេចក្តីសន្និដ្ឋានរបស់ខ្លួនកាលពីមុនថា ច្បាប់អាជ្ញាយុកាលដូចមានចែងនៅក្នុងមាត្រា១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អនុវត្តបានចំពោះតែបទឧក្រិដ្ឋធ្ងន់ធ្ងរធម្មតាប៉ុណ្ណោះ("បទឧក្រិដ្ឋ") គឺមិនមែន

---

[7] ឯកសារលេខ**E58/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ញត្តិរបស់ អៀង សារី សុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារមានកំហុសផ្នែកនីតិវិធី", ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១, ត្រង់កថាខណ្ឌទី២៨-៣១។

[8] ឯកសារលេខ **E306/1** សារណារបស់ នួន ជា ត្រង់កថាខណ្ឌទី២ ["ក្រុមមេធាវីការពារក្តីតទៅនេះយល់ឃើញថា ជាការសមស្របដើម្បីបង្ហាញអំណះអំណាងរបស់ខ្លួន និងមូលដ្ឋានច្បាប់ទាំងមូលដែល [*sic*] ដែលស្របទៅនឹង ខ្លឹមសារដែលបានដាក់ជូន [...] សម្រាប់ អៀង សារី"]។

[9] ឯកសារលេខ **E306/2** សារណារបស់ ខៀវ សំផន ត្រង់កថាខណ្ឌទី៩ និងទី១៨៖ ["...លោក ខៀវ សំផន យល់ស្របទាំងស្រុងនូវអំណះអំណាងរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ..." (ការសង្កត់ន័យបន្ថែមនៅក្នុងច្បាប់ដើម)។ "...លោក ខៀវ សំផន យល់ស្របតាមសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី លោក អៀង សារី ..."].

[10] ឯកសារលេខ **D427/1/30** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១, ត្រង់កថាខណ្ឌទី៧៣, ២១២-២១៣។

[11] សំណុំរឿងលេខ **CF001-** ឯកសារលេខ **E188** សាលក្រម, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ត្រង់កខឋាខណ្ឌទី៤០១-៤០៨។

[12] **E1/5.1** ប្រតិចារឹក (សវនាការបឋម), 15.10.40។

ចំពោះឧក្រិដ្ឋកម្មអន្តរជាតិឡើយ[13]។ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលត្រូវផ្តន្ទាទោសនៅក្រោមច្បាប់អន្តរជាតិ មិនមានចែងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ របស់កម្ពុជាទេ ដូច្នេះមិនត្រូវបានគេពិចារណាថាជា "បទឧក្រិដ្ឋ" ក្នុងគោលបំណងនៃក្រម នេះឡើយ។

៥. សហព្រះរាជអាជ្ញាសូមធ្វើការបញ្ជាក់អះអាងអំពីសេចក្តីសន្និដ្ឋានពីមុនរបស់ខ្លួនថា ការដែលគ្មានពាក្យថា "ដែលគ្មានច្បាប់អាជ្ញាយុកាល" នៅក្នុងមាត្រា៦ នៃច្បាប់ អ.វ.ត.ក គឺជាកំហុសឆ្គងក្នុងពេលតាក់តែង និងក៏មិនឆ្លុះបញ្ចាំងអំពីចេតនាខាងអង្គនីតិបញ្ញត្តិដើម្បីដាក់កម្រិត (ធ្វើឲ្យគ្មានប្រសិទ្ធភាព) ចំពោះយុត្តាធិការរបស់តុលាការដែរ ជាពិសេសទាក់ទងនឹងការរំលោភបំពានធ្ងន់ធ្ងរ។ ដូច្នេះ ភាពមិនច្បាស់លាស់ណាមួយក្នុងមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ឬមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ត្រូវតែបកស្រាយឲ្យស្របទៅតាម៖

(ក). ការប្រគល់យ៉ាងច្បាស់ជូន អ.វ.ត.ក នូវយុត្តាធិការទៅលើអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវដែលបានប្រព្រឹត្តនៅក្នុងអម្លុងឆ្នាំ១៩៧៥-១៩៧៩ បើសិនជាសារណារបស់ក្រុមមេធាវីការពារក្តីត្រូវបានយកតាមនោះ អវតក នឹងមិនអាចធ្វើការចោទប្រកាន់បុគ្គលជនជាប់ចោទនានាពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវបានទាល់តែសោះដែលជាគោលជំហរមួយដែលផ្ទុយគ្នាដោយផ្ទាល់ទៅនឹងលិខិតផង និងទាំងទៅនឹងស្មារតីច្បាប់របស់អ.វ.ត.ក ផង។ គោលជំហរបែបនេះនឹងផ្តល់យុត្តាធិការដូចនៅក្នុងមាត្រា៦ មានលក្ខណៈជាការបន្លំភ្នែកទាំងស្រុង)។

(ខ). ការសន្មត់ដែលថាគោលបំណងនៃការធ្វើច្បាប់ដើម្បីឲ្យស្របទៅនឹងច្បាប់អន្តរជាតិ ដូចអត្ថន័យបង្កប់ក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

(គ) . ប្រការនៃការយល់ព្រមទទួលយកនូវអនុសញ្ញានានានៃទីក្រុងហ្សឺណែវនៅមុនឆ្នាំ១៩៧៥[14] ដោយពុំបានបំរុងទុកនូវខចនីយ។ និង

(ឃ). គោលការណ៍*ត្រូវតែរក្សាតាមការព្រមព្រៀង*ដែលអនុលោមតាមកាតព្វកិច្ចនានានៅក្នុងសន្ធិសញ្ញានេះ(ដូចជា កាតព្វកិច្ចក្នុងការចោទប្រកាន់ពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវ ត្រូវតែបានអនុវត្តដោយស្មោះសរ[15]។ និង

[13] **E1/5.1** ប្រតិចារឹក (សវនាការបឋម), 15.51.19 ["អាស្រ័យហេតុនេះ ច្បាស់ណាស់ថា នេះគឺជាច្បាប់ដែលផ្តល់យុត្តាធិការទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិ ផ្ទុយពីច្បាប់ក្នុងស្រុកចំពោះអំពើប្រព្រឹត្តដែលបញ្ញត្តិជាអំពើព្រហ្មទណ្ឌ"]។

[14] **E1/5.1** ប្រតិចារឹក (សវនាការបឋម), 15.53.21។

[15] មាត្រា២៦, អនុសញ្ញានៃទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា, ឆ្នាំ១៩៦៩, 1155 UNTS 331។

-ការហាមឃាត់ក្រោមច្បាប់អន្តរជាតិស្តីពីការអំពាវនាវសុំដោយរដ្ឋណាមួយឲ្យប្រើនូវច្បាប់លក្ខន្តិកៈក្នុងស្រុករបស់ខ្លួនដើម្បីធ្វើជាយុត្តិកម្មចំពោះការបរាជ័យក្នុងការអនុវត្តតាមកាតព្វកិច្ចនានាដែលនៅក្នុងសន្ធិសញ្ញា(ដូចជាកាតព្វកិច្ចក្នុងការចោទប្រកាន់លើបុគ្គលជនជាប់ចោទនានាពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានានានៃទីក្រុងហ្សឺណែវ)[16]។

៦. នៅក្នុងការគាំទ្រគោលជំហរពីមុនរបស់ខ្លួន ដែលអង្គជំនុំជម្រះនេះធ្លាប់បានទទួលយកដោយត្រឹមត្រូវនូវការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្តីពីការនិរទេស សហព្រះរាជអាជ្ញាសង្កេតឃើញជាដំបូងបង្អស់ថា នៅក្នុងការដំណើរការរឿងក្តីនៅក្នុងពេលជំនុំជម្រះទាក់ទងនឹងការចោទប្រកាន់ថាមានវិការៈផ្នែកនីតិវិធីនៅក្នុងដីកាដំណោះស្រាយ គឺត្រូវបានរារាំងយ៉ាងច្បាស់ដោយវិធាន៧៦(៧) នៃវិធានផ្ទៃក្នុង។ ទីពីរ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរលើសំណុំរឿង០០២ ទាំងសហព្រះរាជអាជ្ញា និងទាំងសហចៅក្រមស៊ើបអង្កេត មិនបានពិចារណាថាការជម្លៀសមនុស្សដោយបង្ខំពីខេត្ត ព្រៃវែង ស្វាយរៀង និង សហករណ៍នៅត្រាំកក់ គឺជា“អង្គហេតុថ្មី” ពាក់ព័ន្ធនឹងវិធាន ៥៥.៣ នៃវិធានផ្ទៃក្នុងដែលដូចគ្នាទៅនឹងមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះទេ។ សំណុំរឿងនេះមិនមានដីកាបញ្ជូនពីអង្គហេតុថ្មីដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតទេនៅក្នុងបញ្ហានេះ។

៧. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមអង្គជំនុំជម្រះសាលាដំបូង មេត្តាបដិសេធចោលនូវអញ្ញត្រកម្មដែលមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានអះអាងនោះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |

[16] មាត្រា២៧, *ដូចគ្នានឹងខាងលើ*។